ពិសោធន៍ដូចខ្ញុំរៀបរាប់ក្នុងចំណុច (1)តាមរយៈវិញ្ញាណទាំង៥ (2)តាមរយៈខួរក្បាល និង(3)តាមរយៈពិសោធន៍វេទនាទាំងឡាយលើរូបកាយ នាពេលនេះ ម៉ោងនេះ នាទីនេះ វិនាទីនេះ គេហៅថា ពិសោធន៍វេទនាពហុញ្ញាណពីខណៈមួយទៅខណៈមួយ Multi sensual sensation experiences moment by moment។ ពិសោធរបៀបនេះមានពិតលើរូបយើងម្នាក់ៗ នាខណៈនេះតែម្តង ថ្វីត្បិតតែពិសោធន៍ទាំងនោះខុសៗគ្នា ហើយប្រែប្រួលជានិច្ចក៏ដោយចុះ។ មនុស្សច្រើន មាននិន្នាការរំលងពុំនឹកភ្លឹកគិតគូរដល់រាល់ហេតុការណ៍ដ៏សាមញ្ញតែមានតម្លៃអស្ចារ្យ ។

ចំណុចកត់សំគាល់ :

(k)បើអ្នកកំពុងអានឯកសារនេះអ្នកតម្រង់សតិមករកខ្លឹមសារវាអ្នកពុំអាចមានពិសោធន៍វេទនាពហុញ្ញាណដ៏ទៃទៀតឡើយ ។ មានន័យថា អ្នកពុំអាចមានពិសោធវេទនាពហុញ្ញាណដ៏ទៃទៀតបាន បើអ្នកពុំបង្វែរសតិដឹងទៅកាន់ទីនោះទេ ។ បើកំពុងស្មុងនឹងអត្ថបទនេះ អ្នកពុំអាចឮស្នូរសត្វយំនាមាត់បង្អួចឡើយ តែបើអ្នកឈប់អានមួយភ្លែតហើយបង្វែរសតិដឹងទៅលើបាតុភូតជុំវិញនោះ អ្នកនឹងទទួលពិសោធសព្វយ៉ាងភ្លាមៗ ដូចជា ឮស្នូរចាបយំ ខ្យល់បក់ស្លឹកឈើ រថយន្តបើកខាងក្រៅផ្ទះសម្លេងនាឡិការប៉ោលតុកតាក់ៗ ឮដំណើរបេះដូងក្តុកៗក្នុងខ្លួន ។ល។ ចំណុចដូចពោលមកនេះ យើងជាមនុស្សមានសិទ្ធិ និងសមត្ថភាពអាចបិត ឬបើកពិសោធន៍វេទនាពហុញ្ញាណទាំងនោះបាន ។ ប៉ុន្តែក្នុងសភាពជាក់ស្តែងយើងច្រើនទំលាប់បិតជិតឈឹងជាហេតុបណ្តាលឱ្យយើងរស់នៅក្នុងរង្វង់ជីវិតតូចចង្អៀតពោរពេញទៅដោយទុក្ខសោករាប់រយពាន់ម៉ឺនសែនជំពូក។ តើទំលាប់បិតជិតឈឹងរបៀបណានោះ ខ្ញុំនឹងជំរាបជូនក្នុងជំពូកក្រោយៗទៀត។

(x) ពិសោធន៍វេទនាពហុញ្ញាណមានពីរយ៉ាង :

(1)ពិសោធន៍វេទនាពហុញ្ញាណដោយពុំផ្ទាល់ indirect multi sensual sensation experiences (2)ពិសោធន៍វេទនាពហុញ្ញាណដោយផ្ទាល់ Direct multi sensual sensation experiences ។

A ពិសោធន៍វេទនាពហុញ្ញាណដោយពុំផ្ទាល់ Indirect multi sensual sensation experiences :

កុមារតូចអាយុកន្លះឆ្នាំឬមួយឆ្នាំ គេមានខួរក្បាលសស្អាតផូរផង់ ដោយពុំទាន់ថតចម្លងអ្វីចូលឡើយ ។ ក្មេងតូចនេះពិសោធវេទនាពហុញ្ញាណដោយផ្ទាល់ ពីព្រោះខួរក្បាលគេនៅទំនេរសស្អាត ។ ខួរក្បាលក្មេងតូចគ្មានពាក្យពេជ្ជ គ្មានសញ្ញាណ គ្មានរូបភាពអ្វីឡើយ ផ្ទៃចិត្តរបស់វាល្អផូរផង់ណាស់ វាពុំស្គាល់ថា ខ្លួនវាជានណាផង វាពុំចេះភូតភរឬមានបំណងអាក្រក់ណាមួយឡើយ ។ បើវាឃើញភ្លើងគឺឃើញតែភ្លើងប៉ុណ្ណោះ វាគ្មានពាក្យសំគាល់ វាពុំយល់ន័យក្តៅ ត្រជាក់ គ្មានគំនិត គ្មានទស្សនទានអ្វីឡើយ (no conceptions)។

លុះដល់ក្មេងតូចនេះចំរើនវ័យធំឡើង គ្រួសារ សាលាសង្គមទាំងមូលបានបញ្ចូលប្រូក្រាម សញ្ញាណ ពាក្យពេចន៍ ទស្សនទាន រឿងរ៉ាវនានា អារ្យធម៌ វប្បធម៌ទៅក្នុងខួរក្បាលវា នាំឱ្យកើតឡើងនូវបុគ្គលិកមនុស្ស Personality ទំលាប់ផ្សេងៗ និន្នាការផ្សេងៗ ទស្សនៈផ្សេងៗ ជំនឿផ្សេងៗ ទៅតាមមជ្ឈដ្ឋានវារស់នៅ។ ឧទាហរណ៍ មនុស្សបីនាក់ឈរនៅពីមុខភ្នំមួយប្រកបដោយព្រៃប្រឹក្សាបៃតងស្រងាត់ ។ ជនទី១ជាពាណិជ្ជករ គាត់គិតឃើញថា ភ្នំនេះគួរយកជាកន្លែងសំរាប់អ្នកទេសចរមកកំសាន្តជាទីមនោរម្យក្រៃលែង ហើយវានឹងបង្កើតចំណូល និងការងារដ៏ច្រើនសំបើម។ ជនទីពីរជាមេចោរគេនិយាយថា ភ្នំប្រកបដោយព្រៃស្រោងបែបនេះ គួរជាទីជំរកសំរាប់លាក់បំពួនទ្រព្យសម្បត្តិ និងរក្សាសុវត្ថិភាពដល់ពួកចោរទៀតផង។ ចំណែកឯជនទីបីជាលោកអាចារដ៏ល្បីឈ្មោះគាត់គិតថា ភ្នំនេះសមជាកន្លែងទីសប់សាត់សំរាប់ស្ងឹងស្ងាត តាំងសមាធិមនុស្សនានាអាចនឹងរកឃើញផ្លូវរួចរំដោះសំរាប់ជីវិត។ ទស្សនៈជនទាំងបីនាក់នេះ ខុសគ្នាអាស្រ័យដោយ គេរស់នៅទីមជ្ឈដ្ឋានប្រវត្តិផ្សេង ទីដ្ឋានផ្សេង ម៉េម៉ូរីការចងចាំកត់ត្រាផ្សេងគ្នា លក្ខខណ្ឌផ្សេង Conditioning phenomenon ។ ការពិសោធន៍វេទនាពហុញ្ញាណ ដែលអាស្រ័យដោយម៉េម៉ូរីជាកត្តាកំណត់ដោយការចងចាំដោយការគិតពិចារណា ដោយប្រើខួរក្បាល ដូចពោលខាងលើនេះ ឈ្មោះហៅថា ពិសោធន៍វេទនាពហុញ្ញាណដោយពុំផ្ទាល់ ។ ឧទាហរណ៍តូចមួយដូចជាអ្នកឃើញផ្កាកូឡាបមួយទងភ្លាមនោះខួរក្បាលអ្នក និងម៉េម៉ូរីដែលអាត់ទុកជាយូរលង់មកហើយបានខ្ទាក់មកក្រៅធ្វើឱ្យស្រមៃឃើញរឿងភាពយន្តក្នុងនោះ បុរសម្នាក់កំពុងហុចផ្កាកូឡាបមួយទងជូនដល់សង្សារអ្នកទទួលអារម្មណ៍ផ្អែមល្ហែមនៃស្នេហារដ៏បរិសុទ្ធប្រហែលពេលនេះអ្នកភ្លេចគិតដល់ផ្កាកូឡាបពិតៗចំពោះមុខនេះទៀតផង។ **តទៅលេខក្រោយ**

ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ
CONWAY INSURANCE

For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត
មុខរបរ និងសុខភាព
យើងនិយាយភាសាខ្មែរ

CONWAY
INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

East Coast Center
for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com

Skin Care Products

Tummy Tuck

Breast Lift

Beast Enlargement

Nose Surgery

Eyelid Surgery

Face Lift

Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា សឺន សាន

ដោយ : ម៉ម យីន

(តពីលេខមុន)

ទើបកងទ័ពយួនក្រហម បានរិះរកវិធីកំចាត់ចោល ចលនាព្រលឹងខ្មែរនេះឱ្យ រលំរលាយទៅវិញ ។

កងទ័ពយួនក្រហមបានយកវិធីដ៏ល្អពិសេសមួយមកអនុវត្តន៍ក្នុងការកំចាត់កំចាយ គឺយួនបានបង្កើតចលនាមួយមានឈ្មោះថា ព្រលឹងខ្មែរដូចគ្នា មានការប្រជុំនិយាយពន្យល់ណែនាំប្រជាពលរដ្ឋខ្មែរដូចគ្នា ។ បន្ទាប់មកយួនបញ្ជូនក្រុមនេះឱ្យចូលកមករួមប្រជុំជាមួយ ចលនាព្រលឹងខ្មែរពិតប្រាកដនេះទៀត បណ្តាលឱ្យមេដឹកនាំចលនាព្រលឹងខ្មែរពុំបានចាប់អារម្មណ៍នឹកស្មានថា ជាចលនារបស់ខ្លួនមានការរីកលូតលាស់កាន់តែខ្លាំងឡើង ហើយក៏ចេះតែធ្វើតៗមក ។

ស្រាប់តែថ្ងៃ១ឃើញកងទ័ពយួននាំគ្នាដើររកចាប់សកម្មជនមួយម្តងៗយកទៅដាក់គុក ។ ពេលនោះហើយ ទើបមានសកម្មជនខ្លះចាប់ផ្តើមដឹងថា ការសម្ងាត់របស់ខ្លួន ត្រូវកងទ័ពយួនការណ៍ដឹងច្បាស់អស់ហើយ ក៏ចាប់ផ្តើមនាំគ្នារត់គេចខ្លួនពួនអាត្មាយ៉ាងភ័យស្លន់ស្លោ រហូតដល់មេដឹកនាំចលនាសំខាន់ៗខ្លះ ត្រូវតែរត់គេចចេញចោលចលនាដែរ មានជាអាទិ៍លោកបណ្ឌិត ហ៊ីងគុនថុន ជាអតីតប្រធានធនាគារជាតិតកម្ពុជា លោកតាន់ គឹមថៃ និងសកម្មជនមួយចំនួនទៀតបានធ្វើដំណើរទៅកាន់ព្រំប្រទេសដែនខ្មែរ-សៀម ដើម្បីទៅរួមរស់ជាមួយរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ដែលកំពុងធ្វើសកម្មភាពប្រយុទ្ធយ៉ាងសកម្មបំផុត ទៅលើកងទ័ពយួនក្រហម និងក្រុមមេដឹកនាំដែលកងទ័ពយួនបានបន្តុបឡើងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នោះ ។

កងទ័ពយួនក្រហមនៅតែធ្វើសកម្មភាពកំចាត់កំចាយចាប់ដាក់គុកសកម្មជនស្នេហាជាតិពិតប្រាកដ ដូច្នេះតើមិនមែនបង្ហាញឱ្យឃើញនិងដឹងថា កងទ័ពយួនក្រហម គឺជាអ្នកចូលមកលុកលុយវាយប្រហារដើម្បីយកប្រទេស និងជនជាតិខ្មែរឱ្យទៅនៅក្រោមការត្រួតត្រាគ្រប់គ្រងរបស់យួនក្រហមទេ ឬអី? ហើយជាការបំបិទសិទ្ធិសេរីភាពជនជាតិខ្មែរទេឬអី ?

នេះហើយ ជានយោបាយដ៏ល្អប្រសើររបស់មេដឹកនាំប្រទេសខ្មែរ ក្រោយឆ្នាំ១៩៥៣ ដែលបានធ្វើឱ្យឯករាជ្យភាពខ្មែរ នៅក្នុងគ្រប់វិស័យ គឺ វិស័យសេដ្ឋកិច្ច វិស័យបូរណភាព និងអធិតេយ្យភាពទឹកដី វិស័យនយោបាយ វិស័យខ្មែរពេញច្បាប់ដោយងាយស្រួលទៀត ហើយ និងមានការរីកចំរើនលូតលាស់ល្អប្រសើរដទៃទៀតជាច្រើនដែលសុទ្ធសឹងពោរពេញទៅដោយការឈានទៅដល់សេចក្តីវិនាសមហន្តរាយដល់ផលប្រយោជន៍របស់ប្រទេសនឹងជនជាតិខ្មែរពិតៗ រហូតបណ្តាលឱ្យប្រទេស និងជនជាតិខ្មែរ និងត្រូវបាត់បង់បន្តិចម្តងៗទៅអនាគតមានន័យថា ប្រទេស និងជនខ្មែរត្រូវតែធ្លាក់ទៅក្នុងអំណាចត្រួតត្រាគ្រប់គ្រងដឹកនាំរបស់ប្រទេសយួននេះពិតប្រាកដណាស់ ចៀសពុំរួចឡើយ ។ ពីព្រោះតាំងពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩មក ប្រទេសយួនវៀតណាមសង្គមនិយមបានទទួលជោគជ័យក្នុងផែនការវៀតណាមរូបនីយកម្មគ្រប់គ្រងប្រទេស និងជនជាតិខ្មែរនេះជាស្ថាពរសព្វគ្រប់អស់ទៅហើយ ។ រួចហើយប្រទេសយួនបានបញ្ជូនមន្ត្រីក្របខ័ណ្ឌថ្នាក់ដឹកនាំគ្រប់គ្រងស្ថាប័នទាំងរដ្ឋបាល

នៅមានតលេខក្រោយ

តមកទំព័រទី ១

សាខាបក្ស សម រង្ស៊ី និងសាខា...

ពីរក៏ធ្លាប់បានចងសម្ព័ន្ធភាភាពជាមួយគ្នាម្តងរួចមកហើយ ប៉ុន្តែចំណងនៃសម្ព័ន្ធភាពនោះត្រូវបានកើតឡើងតែមួយដង្ហើមចង្រិតប៉ុណ្ណោះ ក៏រលត់រលាយដ៏ឆាប់រហ័សបំផុត ។

បន្ទាប់ពីនោះមកបក្សប្រឆាំងទាំងពីរតែងតែវាយប្រហារដោយការឆ្លើយឆ្លង តាមពាក្យសំដីដាក់គ្នាជាហូរហែរ ។ បក្សប្រឆាំងទាំងពីរតែងតែបង្ហាញនូវភាពត្រឹមត្រូវ និងស្អាតស្អំរបស់គេរៀងៗខ្លួន ។ ជានិច្ចជាកាល បក្ស សម រង្ស៊ី តែងតែវាយប្រហារទៅលើបក្សសិទ្ធិមនុស្សថា ជាអាយ៉ងរបស់បក្សកាន់អំណាច ។ រីឯបក្សសិទ្ធិមនុស្សក៏ធ្លាប់បានវាយប្រហារ និងរិះគន់ចំៗចំពោះ លោក សម រង្ស៊ី ប្រធានបក្ស សម រង្ស៊ី ថាគ្មានចេតនា និងគ្មានឆន្ទៈក្នុងការរួបរួម ដើម្បីបំរើដល់លិទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដមួយ ។

ទោះជាយ៉ាងណាក៏ដោយក្រោយពីភ្លៀងមេឃនិងស្រឡះ ហើយចំពោះដំណឹងនៃការរួបរួមគ្នាឡើងវិញរវាងបក្សប្រឆាំងទាំងពីរនេះ បានញ៉ាំងឱ្យមានសាទរ និងគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរដែលស្នេហាលទ្ធិប្រជាធិបតេយ្យទាំងក្នុង និងក្រៅប្រទេស ប៉ុន្តែគេនៅពុំទាន់ដឹងថា តើយន្តការនៃការរួបរួមគ្នានោះ អាចនឹងទទួលបានជោគជ័យ ឬបរាជ័យយ៉ាងណានៅឡើងទេ ៕

ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"
Free Estimate
Auto Body and Maintenance
BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting
មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្ទួរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :
ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services
From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.
4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
Rathe´s Auto Service
State and Emission Inspaction General Repairs and Maintenance
MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY
- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកឺរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ផុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*
5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

នាទី ប្រវត្តិសាស្ត្រ

ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : គីម វិមល

តទៅលេខក្រោយ

.អនុរដ្ឋមន្ត្រី : តាន់ ស៊ិនតូ (ហ្វ)
.រដ្ឋមន្ត្រីយុត្តិធម៌ : ចែម ស្នួន (ប)
.អនុរដ្ឋមន្ត្រី : អ្នកស្រីសម កន្និដ្ឋា (ហ្វ)
.រដ្ឋមន្ត្រីវប្បធម៌ និងវិចិត្រសិល្បៈ :
នុត ណារ៉ាង (ភ្ជាប់ខ្លួននឹងប)
.អនុរដ្ឋមន្ត្រី : មីសែល ត្រាណោ (ហ្វ)
.រដ្ឋមន្ត្រីការងារ និងសង្គមកិច្ច : ស៊ុយ សែម (ប)
.អនុរដ្ឋមន្ត្រី : កាន់ ម៉ន (ហ្វ)
.រដ្ឋមន្ត្រីសាធារណការ : អ៊ឹង គាត (ហ្វ)
.អនុរដ្ឋមន្ត្រី : ត្រាំ អ៊ីវតិក (ប)
.រដ្ឋមន្ត្រីសុខាភិបាល : ហុង ស៊ុនហ៊ត (ហ្វ)
.អនុរដ្ឋមន្ត្រី : ឈា ថាំង (ប)
.រដ្ឋមន្ត្រីអតីតយុទ្ធជន : ព្រហ្ម នាគរាជ (ម)
.អនុរដ្ឋមន្ត្រី : ឆាយ ថន (ប)
.រដ្ឋមន្ត្រីអប់រំជាតិ : ម៉ុម ជិមហ៊ុយ (ប)
.អនុរដ្ឋមន្ត្រី : គុន គីមតេង (ហ្វ)
.រដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ :ថាច់ រ៉េន (ព)
.អនុរដ្ឋមន្ត្រី : ឈា សុង (ប)

២៦កក្កដា ១៩៩៣ : អ៊ិនតាក់ផ្ដើមបើកប្រាក់បៀវត្សរ៍ឱ្យរាជការ និងយោធានៃរាជរដ្ឋាភិបាល -ដែលជាប្រាក់ខែ ខែកក្កដា-សីហា និងកញ្ញា ។ នៅក្នុងសិក្ខាសាលាមួយលោករដ្ឋមន្ត្រីថ្មីនៃក្រសួងហិរញ្ញវត្ថុ សម រង្ស៊ី បានធ្វើសេចក្ដីថ្លែងការណ៍ថា "អំពើពុករលួយមិនអាចដើរទៅមុខបានជាមួយនឹងការប្រកួតប្រជែងខាងសេដ្ឋកិច្ចសេរី និងប្រក្រតីទេ" ។

២៩កក្កដា : អ៊ិនតាក់ទទួលស្គាល់ថា ក្រុមខ្មែរក្រហមធ្វើការកំទេច ស្ពាន ផ្លូវ ថ្នល់ និងផ្លូវដែកក្នុងល្បឿន២ថ្ងៃម្ដង ។

១សីហា ១៩៩៣ : ក្បែរចំណុចកុងត្រូល CTI ខេត្តព្រះវិហារក្រុមខ្មែរក្រហមចេញវាយប្រហារពីដែនដីថៃ យោធាអ៊ិនតាក់ ២១នាក់ ត្រូវបានចាប់ខ្លួន ចំនួន ១១ម៉ោងនៅលើទឹកដីថៃ -នាយទាហានថៃប្រចាំការនៅទីនោះមានការស្និទ្ធស្នាលជាមួយក្រុមខ្មែរក្រហម

៨សីហា : យោធារដ្ឋាភិបាលបានបើកការប្រយុទ្ធដ៏ធំមួយទៅលើតំបន់ដែលខ្មែរក្រហមពង្រឹងការកាន់កាប់របស់ខ្លួននៅកំពង់ធំ-ព្រះវិហារ-សៀមរាប-បន្ទាយមានជ័យ ។ គឺការបញ្ចូលកម្លាំងទ័ពបីរួមគ្នាមានទ័ពបក្សប្រជាជន -បក្សហ៊្វុនស៊ិនប៉ិច និងបក្សលោក សឺន សាន ហើយក្នុងរយៈពេលប្រមាណបីសប្ដាហ៍បានទទួលជោគជ័យយ៉ាងគួរឱ្យកតសម្គាល់ -យោធាខ្មែរក្រហមបានត្រូវឱ្យត្រឡប់មកតំបន់ដើមរបស់ខ្លួនដែលកាន់កាប់មុខឆ្នាំ១៩៩៣ -រដ្ឋាភិបាលភ្នំពេញបានកាន់កាប់ព្រំប្រទល់ខ្មែរ-ថៃស្ទើរតែទាំងអស់ ហើយប្រកាសថា "សៀមបានដឹកទ័ពខ្មែរក្រហមពីចំណុចព្រំដែន១ទៅចំណុច១ទៀត" ។ **តទៅលេខក្រោយ**

នាទី ព្រះពុទ្ធសាសនា

ពុទ្ធប្បវត្តិអមដោយរូបភាព

- ❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
- ❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សិត .អេ.លី
- ❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
- ❖ បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

២១០-បន្តិចក្រោយមក អានន្ទក្រាបបង្គំទូលព្រះដ៏មានព្រះភាគថាៈ បពិត្រព្រះអង្គដ៏ចំរើន ! សូមទ្រង់កុំទាន់ចូលនិព្វានក្នុងកន្លែងដ៏តូចមិនសមរម្យឆ្ងាយពីផ្លូវដូច្នេះអី ។ សូមព្រះអង្គទ្រង់ជ្រើសរើសយកទីក្រុងធំណាមួយក្នុងចំណោមទីក្រុងទាំងឡាយដូចជា ក្រុងរាជគ្រឹះ,សាវត្ថី, ឬក៏ទីក្រុងណាមួយផ្សេងៗទៀត ហើយសឹមទ្រង់យាងចូលនិព្វានក្នុងទីនោះ ។ នៅក្នុងទីកន្លែងទាំងឡាយនោះសម្បូរដោយអ្នកមានអំណាចបុណ្យស័ក្តិ និងទ្រព្យសម្បត្តិដែលសុទ្ធតែជាសាវ័ករបស់ព្រះអង្គ, ពួកគេនឹងទទួលខុសត្រូវលើការចាត់ចែងព្រះសពរបស់ព្រះអង្គ ។

២១១-ព្រះពុទ្ធអង្គជាម្ចាស់ទ្រង់ត្រាស់ទៅកាន់អានន្ទថា "ទេ! មិនបានទេអានន្ទ, ចូរអ្នកកុំនិយាយបែបនេះ! ។ អ្នកមិនគួរយល់ថា ទីនេះជាកន្លែងតូចមិនសំខាន់មិនល្អដូច្នោះឡើយ ។ កាលពីយូរលង់កន្លងទៅហើយទីនេះជាទីក្រុងដ៏រុងរឿងមួយ, ជារាជធានីមួយនៃស្ដេចក្រព័ត្រាធិរាជ ។ ម្នាលអានន្ទ! ចូរអ្នកទៅកាន់នគរកុសិនារាថ្វាយដំណឹងនេះដល់ព្រះរាជា និងប្រាប់ដល់ប្រជាជនទាំងឡាយក្នុងយប់នេះតែម្ដងថា នៅវេលាជិតភ្លឺនៃយប់នេះតថាគតនឹងចូលនិព្វាននៅក្នុងព្រៃនេះ ហើយប្រសិនបើជនទាំងឡាយនោះចង់ឃើញតថាគតសូមឱ្យគេមកមើលតថាគតមុនពេលនោះចុះ" ។ អានន្ទក៏និមន្តទៅកាន់នគរកុសិនារាជាមួយនឹងភិក្ខុទាំងឡាយ ហើយក៏បានថ្វាយដំណឹងនេះដល់ព្រះបាទមល្លៈ និងប្រាប់ដល់ប្រជានុរាស្ត្ររបស់ព្រះរាជាតាមព្រះបន្ទូលនៃព្រះពុទ្ធបរមគ្រូ ។

- ❖ Original Illuatration and Naration in Thai by Gunapayuta.
- ❖ Translation into English by A Lu.
- ❖ Coloring by Yann Fang Lee
- ❖ Translation into Khmer by Bhikkhu Kong Am.

210-Later, Ananda said to the Buddha: Buddha Please do not enter Nirvana in such improper, out-of the way, small place. Please select one of the large cities such as Rajagrha. Sravasti. Vaisali, or some other city and enter Nirvana there. In those place there are many rich and powerful persons who are your disciples they will bear the responsibility for arrangement of your holy remailns.

211-The Buddha said to Annada: No! Ananda , Dont·s say that! You should not think of this place as a small and insignificant and unimportant place. Long ago this was a prosperous metropolis, a capital city, the residence of a Cakravarty King Ananda! Go to Kusinagara and tell king and the people that tonight, during the last watch of the night. the Buddha will enter Nirvana in this forest, and if they wish to, they should come. Ananda went to Kusinagara with serveral bhiksus and told king Malla and his people what the Buddha had said.

ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហង

ជោគជតាប្រចាំសប្ដាហ៍

ឆ្នាំជូត

រាល់ការបំពេញការងាររបស់លោកអ្នក ក្នុងរយៈពេលនេះ សុទ្ធតែផ្ដល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀតនោះគម្រោងការដែលបានត្រៀមទុកជាយូរមកហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

ឆ្នាំឆ្លូវ

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

ឆ្នាំខាល

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណងហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលវិបាកអ្វីឡើយ ៕

ឆ្នាំថោះ

អាចពោលបានថា លោកអ្នកមានសេចក្ដីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្ដី គួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

ឆ្នាំរោង

នៅក្នុងរយៈពេលនេះលោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះ ក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញ ដូរផ្លូវឆ្ងាយប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

ឆ្នាំម្សាញ់

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

ឆ្នាំមមី

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលវិបាកអ្វីនោះឡើយ ៕

ឆ្នាំមមែ

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

ឆ្នាំវក

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

ឆ្នាំរកា

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្ដីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមូលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្អុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ។

ឆ្នាំច

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញគួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្ដាប់ឱវាទគ្នា ៕

ឆ្នាំកុរ

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

តមកទំព័រទី ៣

លេខទី១៧-តើទិវាមាតាមានន័យ...

ម៉ែទុកម្ទីងៗសែនឈឺផ្សា
សង្រេងស្រណោះដឹងយ៉ាងណា!
ឬខ្មែរជីវានាទ្រូងព្រៃ? ។
បាកូនក្នុងជួរទ័ពបារាំង
វាយច្បាំងតតាំងយួនស្រកី
ពេលពពុះទឹកបែកខ្ចាត់ខ្ចាយ
បានាងមានជ័យវិញរដ្ឋា ។
ស្រណោះស្រីខ្មែររង់ចាំប្ដី
សង្ឃឹមមានថ្ងៃបានជួបជួន
បើមិនមកទេនាងបីកូន
រង់ចាំជួបជូនក្លាជាថ្មី ។
ឱម៉ែអើយ! ទុក្ខរបស់នារីរង់ចាំប្ដីវិលវិញមក
ពីច្បាំងសង្គ្រាមជាញជ័យពិតជាទុក្ខសោជនាដកម្ម

នៅមានតលេខក្រោយ

PROUDLY INTRODUCING
KEO LONG
SONG WRITER, MUSICIAN & SINGER
A MUST LISTEN CAMBODIAN-
AMERICAN ROCK AND METAL MUSIC !
AVALIABLE NOW @ CAMBODIAN VIDEO STORES
PHILADELPHIA
RHODE ISLAND
MASSACHUSETTS
To order from whole sale and retails,
please contact: 267-474-7305
267-253-3947
VOL. 1 BY SECRET WEAPON
RELEASED
3/17/2012

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
- សេចក្ដីអន្ដរាយដល់បុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងលែងប្ដីប្រពន្ធ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- Personal Injury
- Disability
- Sex & Drug Crimes, OUI
- Family Law & Divorce
- Traffic Accidents
- Work Accidents

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

មន្ទីរសុខភាព ART OF WELLNESS CENTER
647 Bainbridge St. Phila PA., 19147 **215-305-2238**
ទទួលព្យាបាលខ្លួន និងបញ្ហាផ្លូវចិត្តធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នកដោយប្រើ
របៀបបច្ចេកទេសអាស៊ីនិងបច្ចេកវិទ្យាបច្ចឹមប្រទេស ។

ទទួលព្យាបាលគ្រប់វិធី
- ប្រើម្ជុលឥតថ្នាំ • ចាប់សរសៃ • ចិត្តវិទ្យា • យោគ/ភាវនា

TREATMENT TYPE
- Acupuncture • Acupressure • Psychotherapy • Yoga/ Meditation

www.artofwellnesscenter.com

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :
- Weight Management for Adult & Children
- Diabetes
- High Blood Pressure
- High Cholesterol Level Issue
- Pain Management
- Nutrition Consultation (Free)
- Women´s Health
- គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង
- ទឹកនោមផ្អែម
- លើសសម្ពាធឈាម
- លើសកូរិត កូលេសស្តេរ៉ូល
- ឈឺខ្លួនប្រាណគ្រប់កន្លែង
- ពិគ្រោះពីម្ហូបអាហារ (មិនយកកំរៃ)
- សុខភាពស្ត្រី
- Insomnia (Difficulty Sleeping)
- Feeling Tired & Weak
- Stress /Anxiety
- Depression
- Family Issues
- Addiction Issues
- Anger Management
- ដេកមិនលក់
- អស់កម្លាំង មិនស្រួលខ្លួន
- ភាពតានតឹង/ការថប់អារម្មណ៍
- ធ្លាក់ទឹកចិត្ត
- មានវិបត្តិក្នុងគ្រួសារ
- ការញៀន និងអ្វីមួយ
- មានកំហឹងច្រើន

យើងទទួលយក AETNA នឹង UNITED HEALTHCARE CIGNA

តមកពីទំព័រទី ៨

ប្រេសក្តីបនៅរួបើន...

គឺ២៧ សំឡេង! បានន័យថា បើខ្មែរយើង២៧នាក់ ក្នុងចំណោមខ្មែរប្រមាណខ្មែរប្រមាណ៩០០០នាក់ នៅលីនសម្រេចចិត្តមិនទៅបោះឆ្នោតទេនោះ លោក ហុង ណេត ក៏ពុំអាចអង្គុយអាសនៈនៅទីនេះបានដែរ ខ្ញុំធ្វើការពេញ ពេលនៅបីកន្លែង គឺខ្ញុំជាអ្នក Consultant ផង ជាម្ចាស់ហាងថ្មីមួយផង និងជាបេក្ខជនថែម ទៀត -ធ្វើជាអ្នកនយោបាយគឺជាការទទួលខុសត្រូវ មួយចំពោះមុខសហគមន៍តែចំពោះអ្នកមិនទៅបោះ ឆ្នោតវិញ អ្នកនយោបាយគេមិននិយាយរកទេ ដូច្នេះ ការទៅបោះឆ្នោត គឺការសម្តែងមតិដែលគេគោរព បើលោកអ្នកមានបងប្អូននៅតំបន់ដែលខ្ញុំឈរឈ្មោះ សូមណែនាំពីឈ្មោះខ្ញុំផង ហើយសូមឱ្យបោះឆ្នោត ឱ្យខ្ញុំ ។

កែម ស៊ាយ : ខ្ញុំជាប្រធានគណបក្ស សម រង្ស៊ី ប្រចាំរដ្ឋម៉ាសា-ឈូសែត ខ្ញុំបានទទួលសេចក្តីអញ្ជើញពីខ្មែរផូស ស.រ.អា ខ្ញុំក៏បានណែនាំគ្នាចូលរួមចំនួន២ តុ -ថ្ងៃនេះពុំមានអ្វីជារឿងនយោបាយទេ គឺជារឿងសង្គមដែលខ្ញុំយល់ថា ទោះជាមានទស្សនៈយ៉ាងណាក្តីមាននិន្នាការខុសគ្នាក្តី គឺយើងត្រូវរកវិធីគ្រប់បែបយ៉ាង ដើម្បីឱ្យមានការចុះសម្រុងគ្នារួបរួមគ្នាឱ្យបាន ។ ខ្ញុំសង្កេតឃើញថា ខ្មែរយើងនៅមានការបែងចែកគ្នាមើលបំណាំគ្នាពុំសូវចូលគ្នាចុះទេ តែថ្ងៃនេះខ្ញុំឃើញខ្មែរផូសធ្វើបានល្អណាស់ ដោយខ្ញុំឃើញអ្នកស្រី មាយ៉ា ក៏អញ្ជើញមកលោកប្អូន ស ឆែល ក៏មកចូលរួមឱ្យយោបល់ពីសហគមន៍យ៉ាងស្មើមុខគ្នាដែលសកម្មភាពនេះ គួរតែកើតមានកាន់តែច្រើន ។ ខ្ញុំក៏សូមអំពាវនាវឱ្យទម្លាក់ទំនាស់រវាងគ្នានឹងគ្នាចោលចេញ ហើយចេះអត់ឱនគ្នា ដើម្បីភាពជានាគ្នាត្រឡប់មកវិញបាន ។

ពិន សំខុន : ខ្ញុំចង់ឆ្លើយបញ្ជាក់នឹងលោក គិម ស៊ាយ ថា ការស្វែងរកភាពជានាគ្នា គឺស្ថិតនៅលើភាពសុច្ចរិត យុត្តិធម៌ហើយ បើជានាគ្នាលើផ្លូវខិលខូច ក៏វាមិនអាចស្ថិតស្ថេរដែរ -ដូច្នេះសង្គមយើងត្រូវការភាពត្រឹមត្រូវ ដើម្បីចងគ្នាឱ្យបានរឹងមាំ ហើយម្យ៉ាងទៀត សម្រាប់ខ្មែរផូស ថ្វីត្បិតតែមានរឿងមិនល្អជាច្រើនបានត្រូវលាតត្រដាងជាសាធារណៈយើងប្រកាន់យកមាគ៌ាមួយថា "ទោះជារឿងល្អក្តីអាក្រក់ក្តីយើងសរសេរតែការពិត" ។ ព្រោះការពិតជាកញ្ចក់ឆ្លុះបញ្ចាំងរូបភាពឥតក្លែងក្លាយដែលគេអាចដោះស្រាយបាន ។

សេង លីគង់ : ប្រធានគណកម្មាធិការក្រុងខ្មែរនៅឡូវែល ខ្ញុំមានមោទនភាពដែលបានមករស់នៅឡូវែល ហើយក្រុងខ្មែរបានត្រូវបង្កើតឆ្នាំ២០១២ នេះ យើងត្រូវការខ្មែរផូស ដើម្បីផ្សាយឱ្យបានជ្រួតជ្រាបពីក្រុងខ្មែរ ហើយធ្វើឱ្យគេចង់មកលេងក្រុងយើង ហើយទិញដូរទំនិញនានារបស់ក្រុងយើង -យើងត្រូវការអស់លោកអ្នកទាំងអស់ជ្រោមជ្រែងយើង យើងត្រូវការលោកគណក្រុមប្រឹក្សាក្រុង យើងត្រូវការលោក Councelor ដូចលោក ហុង ណេត ជាដើម្បីធ្វើឱ្យគេស្គាល់តម្លៃនៃក្រុងខ្មែរយើង ដូច្នេះ បើគេមានការលំបាកទៅស្រុកខ្មែរមិនបានយើងយកស្រុកខ្មែរមកទីនេះវិញ ។

សុបិន ពិន : ពិធីយើងបានចប់ជាស្ថាពរ សូមអញ្ជើញពិសារភោជនាហារបន្តដោយរីករាយ ហើយនាងខ្ញុំសូមអរគុណចំពោះវត្តមានរបស់លោកអ្នកទាំងអស់ ៕

SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់គាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម

- Kitchen ចង្ក្រានបាយ
- Livingroom បន្ទប់ទទួលភ្ញៀវ
- Bathroom បន្ទប់ទឹក
- Bedroom បន្ទប់ដេក
- Roofing ដំបូល
- Siding ជញ្ជាំង
- Window បង្អួច
- Door ទ្វារ
- Basement ជាន់នៅក្រោមដី
- Additions បន្ទប់បន្ថែម

Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com

OPEN HOUSE
Sunday, July 15th, 1-3 Pm.
50 washington St. Lowell, MA

ឡូវែល: ផ្ទះគំរូអានានិគមនៅតំបន់ទូល ហើយស្ងប់ស្ងាត់ធ្វើ ហើយថ្មីវិញ ទំហំជាង ១៨០០Sp.fr. បន្ទប់ដេក៧ បន្ទប់ទឹក២ មានព័ទ្ធដោយ "សាយឌីង" និងដំបូលធ្វើថ្មីឡើងវិញ ។ បន្ទប់ទាំងអស់មានដាក់ក្តារឹង ហាដ្វូដហ្វ័រ -ជាន់ទី១ មានបន្ទប់ធំ២ និងបន្ទប់ទឹកធំ១ -នៅជាន់ទី២ មានបន្ទប់ "ម៉ាស្ទ័រ" មួយនឹងបន្ទប់ធម្មតាមួយ ហើយបន្ទប់ទឹកថ្មីក្រាលថ្មកែវ -ផ្ទះបាយថ្មី គ្រឿងប្រើប្រាស់ធ្វើ អំពី Stainless Steel ដែលត្រូវតម្លើង -កន្លែងបោកគក់នៅចំហៀងផ្ទះបាយ ក្រោមដំបូលតែមួយសំរាប់រស់នៅបីជំនាន់ ដែលគួរតែទៅមើល! តម្លៃ ២៤៩.៩០០ដុល្លារ ។ បើកទ្វារឱ្យមើល ១-៣ ល្ងាចថ្ងៃអាទិត្យ១៧មិថុនា អាស័យដ្ឋាន

Open House Sunday 1-3 Pm 7/15. Perfect property for 3 Generations in one household. Completely Renovated colonial, over 1800 Sq. Ft of living space. Sunny, High Ceilings, Spacious and air feeling, 2 Bedrooms & 1 full bath on 1st Floor. Gleaming Hardwood Floors, Master Bedroom and large 2nd bathroom on 2nd flr. Brand New bathroom with marble tile floors. Brand new Large Kitchen with stainless steel appliances (to be install). Laundry Hook up off Kitchen, Brand New roof, Heating system. Ample parking. A Must see! Asking $249,900.

Listing Agent: Michael Feltz

Kathleen Lau Realty. Direct: 978-994-4234, Fax: 978-719-6286

ភ្នំជីសូរ ជារមណីយដ្ឋាន ទេសចរណ៍ប្រវត្តិសាស្ត្រ

ប្រាសាទភ្នំជីសូរមានទីតាំងស្ថិត នៅលើភ្នំជីសូរ ភូមិស្លា ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ។ បើយើងធ្វើដំណើរតាមរថយន្តពីភ្នំពេញ តាមផ្លូវជាតិលេខ២កាត់តាមស្រុកបាទី និងប្រាសាទនាងខ្មៅមានចម្ងាយ៦២គីឡូម៉ែត្រ ដោយត្រូវប្រើរយៈពេលប្រហែលមួយម៉ោងរួចបត់ចូលតាមផ្លូវលំមួយមានចម្ងាយ៥គីឡូម៉ែត្រពីផ្លូវជាតិតែបើធ្វើដំណើរពីទីរួមខេត្តមានចម្ងាយ២៧គីឡូម៉ែត្រ ។

គេអាចមើលឃើញភ្នំជីសូរតាំងពីច្រកចូលទៅភ្នំតាម៉ៅនៅតាមផ្លូវ ជាតិលេខ២ឆ្ពោះទៅទិសខាងត្បូង ប៉ុន្តែភ្ញៀវទេសចរត្រូវបន្តដំណើរប្រមាណ ២៥គីឡូម៉ែត្រទើបទៅដល់ទីនោះ ។ នៅលើភ្នំជីសូរមានប្រាសាទបុរាណមួយ ថ្វីត្បិតតែមានសភាពបាក់បែកភាគច្រើន ប៉ុន្តែវាមានលក្ខណៈល្អផ្តាច់ លើសប្រាសាទនានានៃតំបន់នេះ ។ ពីកំពូលភ្នំនេះគេអាចគយគន់មើលទេសភាពវាលស្រែនៅក្នុងខេត្តតាកែវដ៏ល្អប្រណីតគ្រប់ទិសទី ។

ប្រាសាទភ្នំជីសូរបានស្ថាបនាលើខ្នងភ្នំមួយមានកម្ពស់៣៨០ម៉ែត្រ នៅដើមសតវត្សរ៍ទី១១ (១០០២ -១០៥០) ដោយព្រះបាទសូរ្យវរ្ម័នទី១សម្រាប់ឧទ្ទិសដល់ព្រហ្មញ្ញសាសនា ។ ប្រាសាទនេះសាងសង់អំពីថ្មភក់ និងលីប៉ូនីតមានបណ្តោយ៦០ម៉ែត្រទទឹង៥០ម៉ែត្រ និងមានថែវ២ជាន់ព័ទ្ធជុំវិញ ។ ថែវ ទី២មានទំហំតូចជាងថែវទីមួយ និងនៅចំកណ្តាលមានទីសក្ការៈមួយ ដែលសំខាន់ ហើយមានទ្វារឆ្លាស់ពីរខាងក្នុងមានរូបបដិមាមួយអង្គធ្វើអំពីឈើ ។ ដោយឡែកគេប្រទះឃើញក្បាច់ចម្លាក់យ៉ាងល្អប្រណីតនៅផ្តែរនិងសសរពេជ្រ ។

គេនិយមឡើងភ្នំជីសូរតាមជណ្តើរថ្មខាងលិចដែលមានចំនួន៣៩០កាំ ហើយចុះតាមជណ្តើរខាងត្បូង ដែលមានចំនួន ៤០៨កាំ ។ នៅ ចំពីមុខប្រាសាទមានខ្លោងទ្វារ និងមានជណ្តើរមួយទៀត សាងសង់តាំងពីសម័យកសាងប្រាសាទ ដែលភ្ជាប់ទៅនឹងប្រាសាទសែនធ្លស់ និងប្រាសាទ សែនភូវាំង និងទន្លេអុំដែលជាបឹងដ៏ពិសិដ្ឋកាលពីអតីតកាលសម្រាប់ធ្វើពិធីងូតទឹកលាងបាបតាមលទ្ធិព្រហ្មញ្ញសាសនា ។ ក្រៅពីនេះនៅមានប្រាសាទជាច្រើនទៀត ដែលស្ថាបនាតាមសម័យកាលខុសៗគ្នានៅលើទីលានថ្មមួយដ៏ធំទូលាយបែរមុខទៅទិសខាង កើតនិងពាយ័ព្យមានបណ្តោយប្រវែង១០០ម៉ែត្រ និងទទឹង៨០ម៉ែត្រ ។ ប៉ុន្តែអ្វីដែលគួរឱ្យសោកស្តាយ គឺមួយផ្នែកធំនៃប្រាសាទភ្នំជីសូរត្រូវបានខូចខាត ។

នៅប៉ែកខាងត្បូងនៃប្រាសាទមានព្រះវិហារពុទ្ធសាសនាសង់ថ្មីមួយ និងនៅខាងក្រោយមានសាលាធម្មសភាមួយខ្នងដែលមានកុដិព្រះសង្ឃ និងមានទីសក្ការៈតូចមួយទៀត ហើយមានអាងទឹកចំណាស់មួយធ្វើពីបេតុងជាថ្នាក់ៗ ។

ភ្នំជីសូរជារមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្ររបស់ខេត្តតាកែវ ។ មណ្ឌលនេះបាន និងកំពុងផ្ទុះបញ្ចាំងនូវប្រាសាទបុរាណដែលជាកេរដំណែលវប្បធម៌អរិយធម៌បេតិកភណ្ឌជាតិខ្មែរគួបផ្សំនឹងទស្សនីយភាពធម្មជាតិ និងសមិទ្ធផលសង្គមផ្សេងៗទៀត ក្នុងនោះមានជាអាទិ៍ គឺវត្តភ្នំជីសូរ។ ក្រៅពីនេះគេឃើញមានរូងវិមានចន្ទស្ថិតនៅប្រមាណ១៥០ម៉ែត្រពីខាងត្បូងប្រាសាទភ្នំជីសូរ ។ រូងភ្នំធម្មជាតិនេះមានតាំងពីយូរយារណាស់មកហើយ។ វាជាទីស្ងាត់សម្រាប់ពួកសមណព្រាហ្មណ៍តាំងសមាធិ ឬសម្រាប់ធ្វើធុតង្គដើរចង្ក្រមភាវនាធម៌ ។ កាលពីសម័យសង្គ្រាមក្នុងឆ្នាំ១៩៧០មានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងបណ្តាលឱ្យរូងនេះបិទជិតដោយដុំថ្មធំៗមិនអាចចេញចូលទៀតបានឡើយ ។

ក្រៅពីប្រាសាទគេឃើញមានវត្តភ្នំជីសូរបានកសាងឡើងនៅក្នុងឆ្នាំ ១៩១៧ ដែលមានចៅអធិការវត្តគ្រប់គ្រងតាំងពីដើមរៀងមកមានចំនួន៥អង្គ ។ វត្តនេះត្រូវបានបំផ្លាញខ្ទេចខ្ទីក្នុងសង្គ្រាមឆ្នាំ១៩៧០ហើយចាប់ផ្តើមកសាងជាថ្មីក្នុងឆ្នាំ១៩៧៩ តរៀងមក ៕

សមាគមគាំទ្រគ្រួសារខ្មែរ នឹងខ្មែរជួស ស.រ.អា

អ្នកឯកទេសខាងរុករកបុរាណវត្ថុក្រោមដី បណ្ឌិត ធុយ ចាន់ធួន ខាងបុរាណវិទ្យាមកពីទីក្រុងភ្នំពេញនឹងធ្វើសេចក្តីរាយការណ៍ស្តីអំពីការរកឃើញដ៏ធំមួយដែលនឹងបំភ្លឺពីប្រវត្តិកម្ពុជាឲ្យមានការជាក់ច្បាស់ជាពេលមុនៗពី" អាថ៌កំបាំងនៃអង្គរវត្ត" ដ៏រុងរឿងរបស់ខ្មែរ ។ ភស្តុតាងដែលខ្វះខាតគ្រប់កន្លែងនឹងគ្រប់ជំនាន់នៃប្រវត្តិសាស្ត្រកម្ពុជាបានត្រូវផ្តើមបំពេញដោយការរុករកតាមបែបវិទ្យាសាស្ត្រហើយ បណ្ឌិត ធុយ ចាន់ធួន នឹងមករាយការណ៍ ជូនហ្វីឡា ដែលហ្សៀនៅ :

****Wat Bra buddha Ransy**
619 Ritner Street
Philadelphia, PA 19148
* Tuesday July 17th, 2012
*from 4 to 7PM

You are invited to attend the meeting regarding the "Secret of Angkor Wat" with Dr. THUY CHANTHUON Archeologist, Deputy Director Institute of Culture & Fine Art in Cambodia.

Contacts : : Pin Samkhon Roger 267-770-6982
Soben pin 267-253-3947
Mao Man 215-336-2562
Tray Holl 215-435-9733